ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១២៥

ចុះថ្ងៃទី ២៥ _០២ _១០

សាលដីកា

លេខ : ០១ "ក្រVI អ"

ចុះថ្ងៃទី ២៧_០១_២០១១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១០ រវាង:

- ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅមុនពេលចាប់ខ្លួននៅភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ សាត់ រស់ (ស) ម្តាយឈ្មោះ ណុច ផុល (រ) ប្រពន្ធឈ្មោះ ហែម លីណា កូនគ្មាន ទោសពីមុនមាន ឃាត់ខ្លួនថ្ងៃទី ១៨-១២-២០០៨ ឃុំខ្លួនថ្ងៃទី ១៨-១២-២០០៨។

មានលោក[redacted]ជាមេធាវីការពារ។



Scanned by CamScanner

<u>ជាប់ចោទពីបទ:</u> ផ្ដល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧-០៣-១៩៩៣, ១១-០៤-១៩៩៣ និងថ្ងៃទី ០៤-១០-២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៥០, ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ ៤៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិជម្ពូវ័ន សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ</u>

កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ១៩៩៣, ថ្ងៃទី ១១ ខែមេសា ឆ្នាំ១៩៩៣ និងថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០០៤ ឈ្មោះ [redacted] និងគូកន បានធ្វើកិច្ចសន្យាក្លែងក្លាយ និងស្នាមមេដៃក្លែងដាក់ឈ្មោះ [redacted] ជាម្ចាស់ដីស្ថិតនៅភូមិប៉ាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីលក់ដីនោះមកឱ្យខ្លួន [redacted] ដើម្បីស៊ីជាច់ដីខាងលើពីម្ចាស់ដីដែលមានកម្មសិទ្ធិស្របច្បាប់ ដែលឈ្មោះ [redacted] ពិតប្រាកដពុំបានដឹងខ្លួនឡើយ ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៤ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:**

១- ផ្ដន្ទាទោសឈ្មោ [redacted] ភេទប្រុស អាយុ ៣៨ឆ្នាំ ដាក់ពន្ធនាគារសរុបកំណត់ ៤ឆ្នាំ (បួនឆ្នាំ) គិតបន្តពីសាលក្រមមុន និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០រៀល (បួនលានរៀល) សម្រាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ ផ្ដល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០-០៣-១៩៩៣, ២៦-០៤-១៩៩៣, ១៩-០៥-២០០៤ និងថ្ងៃទី ១១-០៤-១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥០, ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- បង្គាប់ឱ្យឈ្មោ [redacted] សងសំណងការខូចខាត និងជម្ងឺចិត្តគិតជាប្រាក់ចំនួន ៤.០០០.០០០រៀល (បួនលានរៀល) ទៅឱ្យឈ្មោ [redacted] ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានលោក [redacted] ណាង ។ ការសុំលើសពីនេះត្រូវច្រានចោល ។

៣- បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨២ ចុះថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ទៅលោកព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើគូកន និងចាត់ការតាមនីតិវិធី ។

៤- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។



Scanned by CamScanner

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៤ ធ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

<u>អាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)
- លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទ (វត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មកដោយតុលាការក្រុងភ្នំពេញដាក់ទោសខ្លួនធ្ងន់ពេក ហើយការទិញដី និងលុយកាក់ទិញដី គឺតាមរយៈឈ្មោះ [redacted] ហើយខ្លួនពុំដែលប្រគល់លុយឱ្យទៅម្ចាស់ដីផ្ទាល់ទេ។ សំណូមពរ សុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង។

តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: សំណូមពរ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទធ្វើការការពារថា: សំណូមពរ សុំឱ្យក្រុមប្រឹក្សាមេត្តាពិចារណាស្រូបទោសឱ្យកូនក្តីខ្លួនដោយក្តីអនុគ្រោះ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិនិត្យពិភាក្សានិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សភាព្រហ្មទណ្ឌ យល់ឃើញថា**

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមអង្គហេតុបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានផ្តល់សក្ខីភាពក្លែងពិតប្រាកដមែន ខ្លួនមិនស្គាល់ឈ្មោះ [redacted] ទេ ព្រោះខ្លួនបានទទួលលិខិតពី [redacted] ជាអ្នកធ្វើឯកសារឱ្យ។ ពេលនោះឈ្មោះ





Scanned by CamScanner

[redacted] ពុំបានរកស៊ីជាមួយទេ តែក្រោយមកខ្លួនបានសាលក្រមពីតុលាការក៏ទៅពឹងឈ្មោះ [redacted] ឱ្យយកទៅបញ្ចាំឱ្យ ឯឈ្មោះ [redacted] ស៊ីជាមួយខ្លួន ។

៣- ចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ ២២៨ ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៤ ដែលមានឈ្មោះ [redacted] ជាដើមចោទ ហើយមានសាលក្រមលេខ ១៤ ឃ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៤ ហើយឈ្មោះ [redacted] បានសារភាពថា ខ្លួនគាត់ជាអ្នកដែលបានផ្តល់ឯកសារទិញ-លក់ និងឯកសារប្រគល់ប្រាក់ឱ្យទៅតុលាការដើម្បីឱ្យតុលាការពិនិត្យជឿជាក់កាត់ក្តីប្រគល់ដីនោះឱ្យមកខ្លួនប្រាកដមែននេះជាអំពើមួយ គឺជាការផ្តល់សក្ខីភាពក្លែង ។

៤- កិច្ចសន្យាទិញ និងលក់ដី ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ និងលិខិតប្រគល់ប្រាក់ផ្តាច់ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ១៩៩៣ រវាងឈ្មោះ [redacted] ឈ្មោះ [redacted] ពុំមែនជាស្នាមមេដៃរបស់ឈ្មោះ [redacted] ពិតប្រាកដទេ ព្រោះថា ឈ្មោះ [redacted] បានឆ្លើយបដិសេធក្នុងកំណត់ហេតុ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០០៦ ថាខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] និងលក់ដីឱ្យឈ្មោះ [redacted] ដែរ នេះជាអំពើក្លែងលិខិតឯកជនដែលម្ចាស់ឈ្មោះ [redacted] មិនបានដឹងខ្លួន អំពើនេះ គឺជាការក្លែងឯកសាររបស់ឈ្មោះ [redacted] ពិតប្រាកដមែន។

៥- តាមការយល់ឃើញខាងលើ និងភស្តុតាងក្នុងសំណុំរឿងបញ្ជាក់ថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៣ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៤ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៤ និងថ្ងៃទី ១១ ខែមេសា ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥០, ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៦- រឿងក្តីនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ធ្វើការអង្កេត និងលើកយកសំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៧- សាលក្រមព្រហ្មទណ្ឌលេខ ៤៤ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

## ហេតុដូច្នេះ សភាព្រហ្មទណ្ឌ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ថាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្អែកលើអង្គច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៤ ឆ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។





Scanned by CamScanner

៣- បន្តការឃុំខ្លួនជនជាប់ចោទឈ្មោ[redacted]នីតិវិធីច្បាប់ ។

៤- សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១១ កំបាំងមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ ។

បើកសិទ្ធិឱ្យប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា[redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍. ថ្ងៃទី 09 ខែ 02 ឆ្នាំ២០១១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



347